**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

លេខ ៥៥៥ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១០

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការសម្របសម្រួលគម្រោងលើកកំពស់សមត្ថភាព យល់ដឹងអំពីបញ្ហាបរិស្ថាន និងសង្គម លើការងារដោះស្រាយផលប៉ះពាល់ ក្រោមហិរញ្ញប្បទានសហប្រតិបត្តិការផ្នែកបច្ចេកទេសរបស់ទីភ្នាក់ងារ JICA (JICA-TCP)

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និងការកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញកិច្ចព្រមព្រៀងហិរញ្ញប្បទានបច្ចេកទេសរវាងរាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារ JICA ប្រចាំនៅកម្ពុជា ចុះថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០១០
- យោងតាមតម្រូវការចាំបាច់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច

**ប្រការ ១:** បង្កើតគណៈកម្មការសម្របសម្រួលគម្រោងលើកកំពស់សមត្ថភាពការយល់ដឹងអំពីបញ្ហាបរិស្ថាន និងសង្គម នៅក្នុងការងារដោះស្រាយផលប៉ះពាល់ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. **ឯកឧត្តម ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការអន្តរក្រសួង | ប្រធាន និងជានាយកគម្រោង |
| ២. **ឯកឧត្តម តូច ចាន់កុសល** | រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣. **ឯកឧត្តម លឹម ទាន់** | សមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី | អនុប្រធាន |
| ៤. **Mr. Kobayashi Yukiharu** | តំណាងជាន់ខ្ពស់របស់ទីភ្នាក់ងារ JICA ប្រចាំនៅកម្ពុជា | សមាជិក |
| ៥. **បណ្ឌិត ឈន សុភាព** | ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. **លោក អ៊ុំ សិទ្ធីរ៉ា** | អនុប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. **លោក ស៊ុម សំណាង** | អនុប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨. **លោក ឈឹម វណ្ណា** | អធិការ នៃអគ្គាធិការដ្ឋាន នៃក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៩. **លោក ហ៊ីច បញ្ញារុទ្ធ** | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ នៃនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០. **លោក ម៉ែន ដារ៉ាមុនី** | ប្រធានការិយាល័យគំរោងហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគីនៃនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១. **លោក គង់ សុផល** | ប្រធានការិយាល័យបរិដ្ឋាន និងចរាចរដឹកជញ្ជូន នៃក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ១២. **លោក ខឹន រ័ត្នមុន្នី** | អនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ នៃនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | លេខាធិការ |

**ប្រការ ២:** គណៈកម្មការសម្របសម្រួលគម្រោងមានតួនាទី និងភារកិច្ចដូចតទៅ :

១- ត្រួតពិនិត្យលើវឌ្ឍនាការទាំងមូលនៃសកម្មភាពគម្រោង និងលទ្ធផលការងារដែលសម្រេចបាន ។

២- រៀបចំផែនការការងារប្រចាំឆ្នាំរបស់គម្រោង (Annual Work Plan) ឱ្យស្របជាមួយនឹងផែនការប្រតិបត្តិការ (Plan of Operations) ដែលនឹងត្រូវរៀបចំឡើងដោយផ្អែកលើកំណត់ហេតុនៃកិច្ចពិភាក្សា ។

៣- ពិភាក្សាស្វែងរកដំណោះស្រាយសមស្រប ដើម្បីដោះស្រាយរាល់បញ្ហាសំខាន់ៗដែលកើតមានឡើងក្នុងការគ្រប់គ្រងគម្រោង ឬដែលមានទំនាក់ទំនងជាមួយនឹងការគ្រប់គ្រងគម្រោង ។

**ប្រការ ៣៖** កិច្ចប្រជុំគណៈកម្មការត្រូវធ្វើឡើងតាមការចាំបាច់ ឬតាមការអញ្ជើញរបស់ប្រធាន ឬយ៉ាងហោចណាស់ ១ (មួយ) ដងក្នុងមួយឆ្នាំ ដើម្បីបំពេញនូវភារកិច្ចដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ ។ មន្ត្រីតំណាងស្ថានទូតជប៉ុនមួយរូប ឬច្រើនរូបអាចចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មការក្នុងឋានៈជាអ្នកអង្កេតការណ៍ ។

**ប្រការ ៤៖** ឯកឧត្តមប្រធានគណៈកម្មការ និងឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

ចំលងជូន

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងសាធារណការ និងដឹកជញ្ជូន

-ទីភ្នាក់ងារ JICA ប្រចាំនៅកម្ពុជា

- សាមីខ្លួន "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ